ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គបញ្ជាការដ្ឋាន

លេខ ០៤៧/ស.ស.រ
២០១៨

ទីចាត់ការបេឡទូប្បត្ថម្ភ.អបរក
ចូល
លេខ: ១០៧
ថ្ងៃទី ១១/៧ ម៉ោង ៨ ម៉ោង៣០
ឆ្នាំ: ២០១៨

## សេចក្ដីសម្រេច

## ស្ដីពី

## ការបែងចែកភារកិច្ចទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ អគ្គបញ្ជាការដ្ឋាននិងសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ

## អគ្គមេបញ្ជាការស្ដីទី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៩/១៨ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៩/០៦១ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ ស្ដីពីការតែងតាំងមុខងារអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ
- យោងសេចក្ដីសម្រេចលេខ០៨៥/២០១៦ ស.ស.រ. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការបែងចែកភារកិច្ចទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ
- យោងប្រកាសលេខ ១៩២/០៦១៨ ប.ក. ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងការពារជាតិ ស្ដីពីការប្រគល់ភារកិច្ចនាយទាហាន
- យោងតាមសេចក្ដីត្រូវការចាំបាច់នៃការងារចំពោះមុខ

## សម្រេច

**ប្រការ១.-**

ត្រូវបានបែងចែកភារកិច្ចទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំអគ្គបញ្ជាការដ្ឋាននិងសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ ដូចខាងក្រោម៖

១- នាយឧត្ដមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការស្ដីទីជាអ្នកមានសមត្ថកិច្ចក្នុងការបញ្ជាកងយោធពលទាំងមូលនិងជាអ្នកទទួលខុសត្រូវចាត់តាំងអនុវត្តភារកិច្ចការពារជាតិរបស់រាជរដ្ឋាភិបាល ហើយមានភារកិច្ចដឹកនាំ បញ្ជា គ្រប់គ្រងដោយផ្ទាល់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ព្រមទាំងទទួលផ្ទាល់លើការងារខុទ្ទកាល័យ ទីចាត់ការបុគ្គលិក នាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច ទីចាត់ការហិរញ្ញវត្ថុ និងការងារអធិការដ្ឋាន។ ឧត្ដមសេនីយ៍ឯក **ហ៊ឹង ម៉ាណែត** នាយស្ដីទី

សេនាធិការចម្រុះ មេបញ្ជាការស្ដីទីកងទ័ពជើងគោក មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារដឹកនាំ បញ្ជា និងគ្រប់គ្រងកងទ័ពជើងគោក។

២- នាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរង មេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារដឹកនាំ បញ្ជា និងគ្រប់គ្រងបញ្ជាការដ្ឋានអង្គរក្ស។

៣- នាយឧត្តមនាវី **ម៉ិច សំខាន់** អគ្គមេបញ្ជាការរង មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារបញ្ជូនសារនិងបំភ័ន្តអក្ខរៈ។

៤- នាយឧត្តមសេនីយ៍ **សៀង សាផុត** អគ្គមេបញ្ជាការរង មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារមជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា។

៥- នាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** អគ្គមេបញ្ជាការរង នាយកទីចាត់ការហ្វឹកហ្វឺន មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារហ្វឹកហ្វឺននិងអប់រំ ព្រមទាំងជួយការងាររបស់ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត នាយស្ដីទីសេនាធិការចម្រុះ ក្នុងពេលដែលកំពុងបំពេញបេសកកម្ម។

៦- នាយឧត្តមសេនីយ៍ **ម៉ក់ សារុន** អគ្គមេបញ្ជាការរង មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារទំនាក់ទំនងសាធារណៈ។

៧- នាយឧត្តមសេនីយ៍ **ឈិន ច័ន្ទពណ៌** អគ្គមេបញ្ជាការរង មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារសេនាធិការដ្ឋានកងអន្តរាគមន៍។

៨- នាយឧត្តមសេនីយ៍ **សម ប៊ុនថាន** អគ្គមេបញ្ជាការរង មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារព្រំដែន។

៩- នាយឧត្តមសេនីយ៍ **ទ្វាល់ សោម** អគ្គមេបញ្ជាការរង មេបញ្ជាការបញ្ជាការដ្ឋានវិស្វកម្ម មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារដឹកនាំ បញ្ជា និងគ្រប់គ្រងបញ្ជាការដ្ឋានវិស្វកម្ម។

១០- នាយឧត្តមសេនីយ៍ **ម៉ី មរដារី** អគ្គមេបញ្ជាការរង មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារសុខាភិបាលនិងការងារវេជ្ជសាស្ត្រ។

១១- នាយឧត្តមសេនីយ៍ **អ៊ុយ សារិន្ទ** អគ្គមេបញ្ជាការរង មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទីលើការងារអភិវឌ្ឍន៍។

១២- នាយឧត្តមសេនីយ៍ **សឹង សំណាង** អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងអាកាស មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទីលើការងារដឹកនាំ បញ្ជា និងគ្រប់គ្រងកងទ័ពជើងអាកាស និងបញ្ជាការដ្ឋានការពារអាកាស។

១៣- នាយឧត្តមនាវី **ទៀ វិញ** អគ្គមេបញ្ជាការរង មេបញ្ជាការកងទ័ពជើងទឹក មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារដឹកនាំ បញ្ជា និងគ្រប់គ្រងកងទ័ពជើងទឹក។

១៤- នាយឧត្តមសេនីយ៍ **ចាប់ ចាសថា** អគ្គមេបញ្ជាការរង នាយកទីចាត់ការកលយុទ្ធ មានភារកិច្ចជួយអគ្គមេបញ្ជាការស្ដីទី លើការងារផែនការនិងប្រតិបត្តិការសឹក។

១៥- នាយឧត្តមសេនីយ៍ **ណុប គេលា** អគ្គមេបញ្ជាការរង មេបញ្ជាការ បញ្ជាការដ្ឋានកាំភ្លើងធំ មានភារកិច្ចជួយអគ្គមេបញ្ជាការស្តីទី លើការងារដឹកនាំ បញ្ជា និងគ្រប់គ្រងបញ្ជាការដ្ឋានកាំភ្លើងធំ។

**ប្រការ២.-**

ក្រៅពីភារកិច្ចដូចដែលបានបែងចែកខាងលើនេះ នាយស្តីទីសេនាធិការចម្រុះ និងអគ្គមេបញ្ជាការរង ត្រូវទទួលភារកិច្ចបន្ថែមមួយចំនួនទៀត តាមការប្រគល់ពីអគ្គមេបញ្ជាការស្តីទី។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន មេបញ្ជាការប្រភេទទ័ពនិងទ័ពជំនាញ នាយកស្ថាប័នចំណុះ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ១២កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០១៨

**អគ្គមេបញ្ជាការស្តីទី**

នាយឧត្តមសេនីយ៍ សៅ សុខា

**កន្លែងទទួល៖**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
  (ដើម្បីជូនជ្រាប)
- ដូចប្រការ៤
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ